ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
លេខ:.......១៥៩.........ប្រក/ដនស

# ប្រកាស
## ស្តីពី
## ឯកសណ្ឋាន និងសញ្ញាសំគាល់សំរាប់មន្ត្រី
## នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

* * * * *

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើរដ្ឋធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/ ០៧០៤ /១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/ នស/ ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/ រកម/ ០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីកម្ម និងសំណង់

-យោងតាមការចាំបាច់របស់ក្រសួង

## សំរេច:

**ប្រការ១. –**

បង្កើត និងកំណត់ឯកសណ្ឋាន និងសញ្ញាសំគាល់សំរាប់មន្ត្រី នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីប្រតិបត្តិការ និងចូលរួមក្នុងពិធីផ្លូវការផ្សេងៗ។

**ប្រការ២. —**

ឯកសណ្ឋានមន្ត្រី នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវបានកំណត់ដូចខាងក្រោម:

**ក ឯកសណ្ឋានសំរាប់បុរសៈ**

-អាវដៃខ្លី ឬដៃវែង អាវនីមួយៗមានពណ៌ស ឬពណ៌កាគី ចោះរន្ធឡេវមុខមានប៉ូលស្មាទាំងសងខាង មិនឱ្យរលុងពេក សំរុងជើងអាវត្រង់ស្មើ និងមានជីបខ្នង ១ សងខាង។ អាវនេះមានហោប៉ៅខាងលើពីរ (ដេរប៉ះ) បត់ផ្នត់កណ្តាលមួយ មានគំរបហោប៉ៅរាងស្លឹកពោធិ៍ និងដាក់ឡេវជ័រពណ៌ដូចអាវ។

-ខោជើងវែងពណ៌ទឹកប៊ិចចាស់ ដេរថ្នេរបង្កប់ ចង្កេះត ជីបភ្លៅខាងមុខពីរ មានហោប៉ៅបី។ ហោប៉ៅខាងក្រោយមួយដេរបង្កប់ មានគំរបរាងស្លឹកពោធិ៍ ចោះរន្ធដាក់ឡេវចំនួន ១ និងហោប៉ៅចំហៀងទាំងសងខាង ដេរបង្កប់តាមថ្នេរ។

—មួកមានពីរប្រភេទគឺ

**+ មួកការពារសុវត្ថិភាពៈ**

សំរាប់ពាក់ជាមួយឯកសណ្ឋានការងារនៅក្នុងការដ្ឋានសំណង់ ដែលផលិតឡើងអំពីជ័រមានពណ៌ស ។

**+ មួកកាស្កេតៈ**

សំរាប់ពាក់ជាមួយឯកសណ្ឋានការងារ ក្នុងពេលបំពេញបេសកកម្ម។មួកកាស្កេត ពណ៌កាគីមានក្បាំងមុខ និងនៅផ្នែកខាងលើមានដេរជីបរាងជាប្រាំបីជ្រុង ហើយមានចោះរន្ធពីរទាំងសងខាង។

—ស្បែកជើង កខ្លី ពណ៌ខ្មៅចងខ្សែ និងស្រោមជើងពណ៌ទឹកប៊ិចចាស់។

—ខ្សែក្រវ៉ាត់ពណ៌ខ្មៅ ។

**ខ.ឯកសណ្ឋានសំរាប់ស្ត្រីៈ**

-សំពត់ហ្ស៊ីបជីមីស្ការ៉េ ពណ៌ទឹកប៊ិចចាស់ ពាក់កណ្តាលកំភួនជើង ចង្កេះតខាងមុខមានចាប់ផ្នត់ និងខាងក្រោយមានរែក។

-អាវដៃវែង ឬដៃខ្លី អាវនីមួយៗមានកតាំង ឬកឌុប មានពណ៌ស និងពណ៌កាគី

-ស្បែកជើងពណ៌ខ្មៅគ្មានចងខ្សែ (អេស្កាប៉ាំង) និងស្រោមជើងពណ៌ទឹកប៊ិចចាស់។

**ប្រការ៣. —**

ផ្លាកសញ្ញា និងផ្លាកឈ្មោះរបស់មន្ត្រីត្រូវបានកំណត់ដូចខាងក្រោម:

**១ អំពីផ្លាកសញ្ញាដាក់នៅលើដើមដៃអាវ**

ផ្លាកសញ្ញានេះមានពីរប្រភេទគឺ:

**ក ផ្លាកសញ្ញាសំគាល់ក្រសួង**

ផ្លាកសញ្ញានេះមានរាងមូលជារង្វង់(O)មានអង្កត់ផ្ចិតប្រវែង៨ ស.ម មានរឹមខាងក្រៅពណ៌ទឹកប៊ិចចាស់ប្រវែង ០,១ ស.ម ។ រង្វង់ផ្នែកខាងក្នុងមានអង្កត់ផ្ចិតប្រវែង ៦ ស.ម រឹមខាងក្រៅមានប្រវែង ០,១ ស.ម ពណ៌ទឹកប៊ិចចាស់ ។ នៅក្នុងរង្វង់មានរូបដែកឈានពណ៌សរឹមពណ៌ខ្មៅ និងរូបផែនទីនៃព្រះរាជាណាចក្រកម្ពុជាមានផ្ទៃពណ៌ស រឹមពណ៌ក្រហម ឯផ្ទៃខាងក្រៅជុំវិញផែនទីមានពណ៌ផ្ទៃទឹកសមុទ្រ។ នៅចន្លោះរវាងរង្វង់ខាងក្រៅ និងខាងក្នុងមានប្រវែង ១ ស.ម និងមានផ្ទៃពណ៌ស ដែលផ្នែកខាងលើកោងតាមរង្វង់មានសរសេរអក្សរខ្មែរជាអក្សរមូលថា " **ព្រះរាជាណាចក្រកម្ពុជា** " ខ្នាត ៣៦ (Limon R1 Font size ៣៦ )ពណ៌ទឹកប៊ិចហើយផ្នែកខាងក្រោមកោងតាមរង្វង់ មានសរសេរអក្សរខ្មែរជាអក្សរមូលថា" **ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**" ខ្នាត ១៨ ( Limon R1 Font size ១៨) ពណ៌ទឹកប៊ិច ផ្លាកសញ្ញានេះដាក់នៅដើមដៃអាវខាងឆ្វេង ។

**ខ ផ្លាកសញ្ញាសំរាប់មន្ត្រីថ្នាក់ខេត្ត ក្រុង**

ផ្លាកសញ្ញានេះមានរាងជាអក្សរអ៊ុយបិទ(U)ពីលើចុះក្រោមមានប្រវែង៨,៥ ស.ម និងពីឆ្វេងទៅស្តាំមានប្រវែង ៧ ស.ម មានវ័ណ្ឌពីរជាន់ ពណ៌ទឹកប៊ិច ចន្លោះរវាងវ័ណ្ឌខាងក្រៅ និងខាងក្នុងមានប្រវែង ០,៥ ស.ម មានផ្ទៃពណ៌ស ។ នៅខាងក្នុងផ្នែកខាងលើនៃសញ្ញា( U) មានសរសេរអក្សរថា"**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**" និងខាងក្រោមមានសរសេរថា"**មន្ទីរ ដ.ន.ស.ស** និងឈ្មោះខេត្តក្រុង"ដែលមានទំហំអក្សរខ្នាត២៤(Limon R1 Font size 24) នៅខាងក្នុងផ្នែកខាងក្រោមនៃសញ្ញា(U) មានរូបសញ្ញារបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។ រូបសញ្ញានេះមានរាងមូលមានអង្កត់ផ្ចិតប្រវែង៤ស.ម រឹមខាងក្រៅមានប្រវែង ០,០៥ ស.ម ពណ៌ទឹកប៊ិចចាស់ ។ ក្នុងរង្វង់មូលមាន រូបដែកឈានពណ៌សរឹមពណ៌ខ្មៅ និងមានរូបផែនទីនៃព្រះរាជាណាចក្រកម្ពុជាដែលមានផ្ទៃពណ៌សរឹមពណ៌ក្រហមនិងផ្ទៃខាងក្រៅជុំវិញផែនទីមានពណ៌ផ្ទៃមេឃ ។ ផ្លាកសញ្ញានេះដាក់នៅដើមដៃអាវខាងស្តាំ បន្ថែមលើផ្លាកសញ្ញា សំគាល់ក្រសួងដែលដាក់នៅខាងឆ្វេង ។

**២ អំពីផ្លាកឈ្មោះ**

ផ្លាកឈ្មោះនេះមានពីរប្រភេទគឺ:

**ក សំរាប់មន្ត្រីថ្នាក់ក្រសួង**

ផ្លាកឈ្មោះសំរាប់ពាក់នៅលើហោប៉ៅអាវខាងស្តាំ មានរាងបួនជ្រុងទ្រវែងបណ្តោយ

ប្រវែង ៩ ស.ម និងទទឹងប្រវែង ២.៥ ស.ម ធ្វើអំពីជ័ររឹងថ្លាមានពណ៌ទឹកសមុទ្រ និងមានខ្សែបន្ទាត់ពណ៌មាសទំហំ ០,១៥ ស.ម ព័ទ្ធជុំវិញ។ នៅខាងស្តាំនៃផ្លាកឈ្មោះ មានរូបសញ្ញាសំគាល់ក្រសួង មានរាងជារង្វង់ រំលេចដោយវ័ណ្ណ និង អក្សរពណ៌មាស (ដូចរូបសញ្ញានៅដើមដៃអាវខាងឆ្វេង) ដែលមានអង្កត់ផ្ចិតទំហំ ២ ស.ម ។

នៅខាងឆ្វេងនៃរូបសញ្ញានេះ ជួរខាងលើសរសេរនាមត្រកូល និងនាមខ្លួនជាអក្សរមូលខ្មែរ ពណ៌ទឹកមាសផុសថា " <u>**លោក.**ទំហំ ២២ (Limon R1Font size 22)</u> នាមត្រកូលនិងនាមខ្លួនទំហំ៣០ <u>(Limon R1Font size 30)</u>" និងខាងក្រោមសរសេរនាមត្រកូលនិងនាមខ្លួនជាអក្សរឡាតាំង ( Time New Roman ) ពណ៌ទឹកមាសផុសថា" <u>Mr. ទំហំ ១១ (Font size 11)</u>នាមត្រកូល និង នាមខ្លួនទំហំ ១២ <u>(Font size 12)</u> " និងខាងក្រោមអក្សរឡាតាំងមានអត្តលេខសំគាល់មន្ត្រីរបស់ក្រសួង រវាងឈ្មោះនិងរូបសញ្ញា ខណ្ឌគ្នាដោយបន្ទាត់ឈរពណ៌មាសផុសទំហំ ០,១ ស.ម។

**ខ <u>សំរាប់មន្ត្រីថ្នាក់ខេត្ត ក្រុង</u>**

ផ្លាកឈ្មោះសំរាប់ពាក់នៅលើហោប៉ៅអាវខាងស្តាំ មានរាងបួនជ្រុងទ្រវែងបណ្តោយប្រវែង ៩ ស.ម និងទទឹង ២.៥ ស.ម ធ្វើអំពីជ័ររឹងថ្លាមានពណ៌ទឹកសមុទ្រ និងមានខ្សែបន្ទាត់ពណ៌មាសទំហំ ០.១៥ ស.ម ព័ទ្ធជុំវិញ។ នៅខាងស្តាំនៃផ្លាកឈ្មោះ មានរូបសញ្ញាសំគាល់មន្ត្រីថ្នាក់ខេត្ត ក្រុង មានរំលេចដោយវ័ណ្ណ និង អក្សរពណ៌មាស (ដូចរូបសញ្ញានៅដើមដៃអាវខាងឆ្វេង) ដែលមានកំពស់ពីលើចុះក្រោមប្រវែង ២ ស.ម និង ពីឆ្វេងទៅស្តាំប្រវែង ១.៥ ស.ម។

នៅខាងឆ្វេងនៃរូបសញ្ញានេះ ជួរខាងលើសរសេរនាមត្រកូល និង នាមខ្លួនជាអក្សរមូលខ្មែរ ពណ៌ទឹកមាសផុសថា " **លោក.**ទំហំ ២២ <u>(Limon R1 Font size 22)</u> នាមត្រកូលនិងនាមខ្លួនទំហំ៣០ <u>(Limon R1Font size 30)</u>" និងខាងក្រោមសរសេរនាមត្រកូលនិងនាមខ្លួនជាអក្សរឡាតាំង ( Time New Roman ) ពណ៌ទឹកមាសផុសថា" <u>Mr. ទំហំ ១១ (Font size 11)</u>នាមត្រកូល និងនាមខ្លួនទំហំ១២ <u>(Font size 12)</u> "និងខាងក្រោមអក្សរឡាតាំងមានអត្តលេខសំគាល់មន្ត្រីរបស់ខេត្ត ក្រុង រវាងឈ្មោះនិងរូបសញ្ញា ខណ្ឌគ្នាដោយបន្ទាត់ឈរពណ៌មាសផុសទំហំ ០.១ ស.ម។

**ប្រការ៤. –**

ឯកសណ្ឋានការងារមន្ត្រីបច្ចេកទេសនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្ត ក្រុង ដែលបំពេញការងារតាមការិយាល័យ

ធ្វើការ ពុំចាំបាច់ប្រើប្រាស់មួកទាំងពីរប្រភេទខាងលើនេះទេ ។

**ប្រការ៥. –**

ឯកសណ្ឋានការងារពីរសម្រាប់គឺ ដៃវែង ១ សម្រាប់ និងដៃខ្លី ១ សម្រាប់ សំរាប់រយៈពេល ១ ឆ្នាំ ដើម្បីប្រើប្រាស់បំពេញការងារប្រចាំថ្ងៃ ប្រជុំការងារ ទិវាបុណ្យជាតិ និងប្រតិបត្តិការត្រួតពិនិត្យការងារជំនាញ ។

**ប្រការ៦. –**

ជនណាក្លែងបន្លំស្លៀកពាក់ឯកសណ្ឋាន និងសញ្ញាសំគាល់របស់មន្ត្រីនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

**ប្រការ៧. –**

នាយកខុទ្ទកាល័យ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន ប្រធានអង្គភាពចំណុះក្រសួង និងប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី គ្រប់ខេត្ត ក្រុង ត្រូវអនុវត្តប្រកាសនេះអោយមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ, ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៤

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

**អ៊ឹម ឈុនលឹម**

**ចំលងជូន:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់សាលាខេត្ត ក្រុង
- ដូចប្រការ ៧
- ឯកសារ កាលប្បវត្តិ




# ផ្លាកសញ្ញាសំគាល់ក្រសួង




**ផ្លាកឈ្មោះសំរាប់ពាក់ភ្ជាប់ផ្នែកខាងលើហោប៉ៅអាវខាងស្តាំ**
**សំរាប់មន្ត្រីថ្នាក់កណ្តាល**

-ឈ្មោះពណ៌ទឹកមាស អក្សរផុស
-ស៊ុមពណ៌ទឹកមាស ផុស




**រូបសញ្ញាមូលសំរាប់ការដ្ឋានសំណង់**




**ផ្លាកសញ្ញាដេរភ្ជាប់ដៃអាវខាងឆ្វេង**








# ផ្លាកសញ្ញាសំរាប់មន្ទីរខេត្ត ក្រុង




**ផ្លាកឈ្មោះសំរាប់ពាក់ភ្ជាប់ផ្នែកខាងលើហោប៉ៅអាវខាងស្តាំ សំរាប់មន្ត្រីថ្នាក់ ខេត្ត ក្រុង**

-ឈ្មោះពណ៌ទឹកមាស អក្សរផុស

-ស៊ុមពណ៌ទឹកមាស ផុស




**រូបសញ្ញាលើមួកសំរាប់ការដ្ឋានសំណង់**




**ផ្លាកសញ្ញាដេរភ្ជាប់ដៃអាវខាងស្តាំ សំរាប់មន្ត្រីថ្នាក់ ខេត្ត ក្រុង**





